គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ៧៤ ចេញផ្សាយថ្ងៃទី២ ខែមករា ឆ្នាំ២០២៤
No. 74 Released on January 2, 2024

អត្ថបទប្រចាំសប្តាហ៍ | Weekly Article

# តើអ្វីទៅជាបរធនបាលកិច្ចសត្វចិញ្ចឹម?

## What is a Pet Trust?




https://www.theorlandolawgroup.com/wp-content/uploads/2022/07/Pet-Trusts-587x321.jpg

**បរធនបាលកិច្ចសត្វចិញ្ចឹម** (Pet Trust) គឺជាកិច្ចព្រមព្រៀងផ្លូវច្បាប់មួយ ដែលផ្តល់ការថែទាំ និងថែរក្សាសត្វចិញ្ចឹម ក្នុងករណីម្ចាស់សត្វមានពិការភាព ឬមរណភាព។

បរធនបាលកិច្ចសត្វចិញ្ចឹមនេះ ត្រូវបានបង្កើតឡើងដើម្បីធានាឱ្យបានថាសត្វចិញ្ចឹមរបស់ពួកគេអាចទទួលបានការមើលថែទាំ និងថែរក្សាបន្តយូរទៅមុខទៀត ក្នុងករណីម្ចាស់ក្លាយជាអសមត្ថភាពក្នុងការបន្តថែទាំដោយខ្លួនឯង ឬទទួលមរណភាព។ អ្នកដែលបង្កើតបរធនបាលកិច្ចនេះ ហៅថាបរធនបាលទាយក និងអ្នកគ្រប់គ្រងមូលនិធិនេះហៅថា បរធនបាល។ បរធនបាលកិច្ចនេះ អាចមានប្រសិទ្ធភាពទាំងក្នុងអំឡុងពេលម្ចាស់នៅមានជីវិត ឬបន្ទាប់ពីទទួលមរណភាព។ ជាធម្មតា បរធនបាល នឹងជាអ្នកកាន់កាប់ទ្រព្យសម្បត្តិ(ឧ.ទា. សាច់ប្រាក់) ក្នុងបរធនបាលកិច្ចសម្រាប់ម្ចាស់សត្វចិញ្ចឹម ឬសត្វចិញ្ចឹមផ្ទាល់ ដែលនឹងធ្វើការទូទាត់ជាប្រចាំទៅឱ្យអ្នកថែទាំដែលត្រូវបានតែងតាំងក្នុងបរធនបាលកិច្ច។ បរធនបាលទាយកដែលជាម្ចាស់សត្វចិញ្ចឹម អាចគូសបញ្ជាក់ពីរបៀបនៃការថែទាំ ប្រភេទចំណី កាលវិភាគពិនិត្យសុខភាព ឈ្មោះពេទ្យសត្វដែលទទួលខុសត្រូវលើសុខភាពសត្វចិញ្ចឹមរបស់ពួកគេជាដើម។

Pet Trust is a legal agreement that provides care and maintenance of pets in the event of an owner's disability or death.

Pet Trust is created to ensure that their pets can continue to receive care and maintenance in case the owner becomes incapacitated to continue to take care of them or passed away. The person who created the trust is called trustor and the person who manages the fund is called trustee. The trust can be effective either during the owner's lifetime or after death. Typically, the trustee will be the holder of assets (i.e., Cash) in trust for the trustor's pet or the pet and will make regular payments to caregivers as assigned in the trust. The trustor can outline about how the pet is taken care of, type of food, schedule for health screening, veterinarian that will be responsible for their pet's health and so on.

**អត្ថបទ÷ លីម សុពិសី | Article: LIM Sopisey**

**ឯកសារយោង | References:**

-https://larrygriggs.com/pet-trust-primer/
-https://www.aspca.org/pet-care/pet-planning/pet-trust-primer
-https://www.thebalancemoney.com/pet-trust-5188870

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.